**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៥៧. សសរ

# អនុក្រឹត្យ

ស្តីពី

***ការបង្កើតរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស***

**MANHATTAN (Svay Rieng) SEZ**

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រមលេខ ០៣ នស/៩៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៤ និងច្បាប់ស្តីពីវិសោធនកម្មច្បាប់វិនិយោគ ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រមលេខ នស/រកម/ ០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣
- យោងអនុក្រឹត្យលេខ៧០ អនក្រ.បក ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងអនុក្រឹត្យលេខ ១១១ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៥ ស្តីពីការអនុវត្តន៍ច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

## សម្រេច

**ប្រការ១:** បង្កើត*រដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស* MANHATTAN (Svay Rieng) SEZ ដែលមានទីតាំងស្ថិតនៅឃុំបាវិត និងឃុំបាទី ស្រុកចន្ទ្រា ខេត្តស្វាយរៀង ដោយមានសមាសភាព ដូចខាងក្រោម :

| | | |
|---|---|---|
| ១- | តំណាង ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ប្រធាន |
| ២- | តំណាង ក្រសួងពាណិជ្ជកម្ម | អនុប្រធាន |

៣- តំណាង ទីចាត់ការគយ និងរដ្ឋាករ — អនុប្រធាន

៤- តំណាង ក្រសួងមហាផ្ទៃ "*នគរបាល*" — សមាជិក

៥- តំណាង ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ — សមាជិក

សមាជិក*រដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស* ទាំងអស់ ត្រូវអញ្ជើញចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ឬអនុប្រធាន ក្នុងករណីប្រធានអវត្តមាន ។

**ប្រការ២:** *រដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស* នេះ មានភារកិច្ចសំខាន់ៗ ដូចខាងក្រោម :

- ពិនិត្យសំរួលការងារ ជូនអ្នកវិនិយោគនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស ទៅតាមភារកិច្ចនៃសមត្ថកិច្ចរៀងៗខ្លួន ដោយអនុវត្តយន្តការ "ច្រកចេញ-ចូលតែមួយ" នៅនឹងកន្លែង ។
- ធ្វើការត្រួតពិនិត្យលើការនាំចូលទំនិញទៅក្នុងតំបន់សេដ្ឋកិច្ចពិសេស ក៏ដូចជាការនាំចេញទំនិញពីតំបន់សេដ្ឋកិច្ចពិសេស និងធ្វើការសំរេច ក្នុងនាមក្រសួង-ស្ថាប័នរៀងៗខ្លួននៅនឹងកន្លែង តាមលក្ខណៈបច្ចេកទេស និងតាមនីតិវិធីកំណត់ ដោយគ្រាន់តែធ្វើរបាយការណ៍ស្តីពីលទ្ធផលការងារ ជូនថ្នាក់ដឹកនាំរៀងៗខ្លួនប៉ុណ្ណោះ ពោលគឺពុំមានការលើកសំណើសុំការសំរេចពីថ្នាក់លើទៀតឡើយ លើកលែងតែមានបាតុភាពមិនប្រក្រតី ។

**ប្រការ៣:** សេចក្តីសំរេចនេះ ជាបទប្បញ្ញត្តិសំរាប់អនុវត្តនៅក្នុងកាលៈទេសៈចាំបាច់ចំពោះមុខ ដែលពុំទាន់មានច្បាប់ និងអនុក្រឹត្យស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេសប៉ុណ្ណោះ ហើយនឹងអាចធ្វើការកែប្រែអោយស្របតាមបទប្បញ្ញត្តិនានា ពាក់ព័ន្ធតំបន់សេដ្ឋកិច្ចពិសេស ដែលនឹងត្រូវដាក់អោយអនុវត្តនាពេលខាងមុខ ។

**ប្រការ៤:** សហប្រធាន "គ.អ.ក" - រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី-សហរដ្ឋមន្ត្រីក្រសួងក្រសួងមហាផ្ទៃ-រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ-រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម-រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ-រដ្ឋមន្ត្រីគ្រប់ក្រសួង-អភិបាលខេត្តស្វាយរៀង-គ្រប់ប្រធានស្ថាប័ន-មន្ទីរ និងក្រុមហ៊ុន MANHATTAN INTERNATINAL CO., LTD. មានភារកិច្ចអនុវត្តសេចក្តីសំរេចនេះ តាមភារកិច្ចរៀងៗខ្លួន អោយមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ធ្នូ ឆ្នាំ ២០០៥

ហ៊ុន សែន

__កន្លែងទទួល__

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី សហប្រធាន "គ.អ.ក"
- ខុទ្ទកាល័យសម្តេចក្រុមព្រះ សហប្រធាន "គ.អ.ក"
- ដូចប្រការ៤ "ដើម្បីសហការអនុវត្ត"
- ឯកសារ-កាលប្បវត្តិ